

# ជំពូកទី ៧
# បំណិនការគិត

កុមារអភិវឌ្ឍបំណិនការគិតដោយសារគេមានឱកាសជាច្រើនដើម្បីលេងកំសាន្តជាមួយមនុស្សម្នា និងវត្ថុទាំងឡាយដែលនៅជុំវិញខ្លួនគេ។ សកម្មភាពណាក៏ដោយដែលជួយឱ្យកុមាររៀន ផ្តល់ឱ្យគេនូវវិធីថ្មីៗដើម្បីគិតពីព្រឹត្តិការណ៍ទាំងឡាយ។ ជំពូកនេះផ្តល់គំនិតមួយចំនួនសំរាប់សកម្មភាពដែលអាចជួយកុមារដើម្បីអភិវឌ្ឍបំណិនការគិត។ កុមារដែលមើលឃើញស្ទើរតែទាំងអស់ចាប់ផ្តើមរៀនបំណិនការគិតនៅវ័យប្រមាណដូចឧទាហរណ៍ខាងក្រោមនេះ :-





រវាងអាយុ 6 ទៅ 9 ខែ ទារកបានដឹងថាទីនោះនៅតែមានវត្ថុ ទោះបីនៅពេលគេលែងមើលឃើញ, ប៉ះ, ស្តាប់ឮ ឬ ធុំក្លិនពួកវាក៏ដោយ។ ឧទាហរណ៍ បើកុមារធ្វើពែងជ្រុះ គេដឹងថាវាមិនបាត់ឡើយ តែឥឡូវនេះវាកំពុងនៅនឹងដី។

នៅអាយុ 9 ខែ ទារកចាប់ផ្តើមធ្វើត្រាប់តាមអ្វីដែលអ្នកឯទៀតបានធ្វើ។

រវាងអាយុ 9 ទៅ 12 ខែ ទារកដឹងថាគេអាចធ្វើឱ្យអ្វីមួយកើតឡើង។ ឧទាហរណ៍ គេដឹងថា បើគេគោះពែងជាមួយនឹងស្លាបព្រា នោះវាធ្វើឱ្យមានសម្លេង។ ហើយទារកក៏ចាប់ផ្តើមចេះដោះស្រាយបញ្ហាងាយៗផងដែរ។



នៅអាយុមួយឆ្នាំ ទារកអាចផ្តិតផ្គូវវត្ថុពីរដែលដូចគ្នា។ ក្រោយមកទៀត ទារកនឹងរៀនដាក់តាមលំដាប់ និងរាប់វត្ថុ។



កុមារដែលមិនអាចមើលឃើញច្បាស់ ក៏អាចរៀនបំណិនទាំងនេះបានផងដែរ។ ជាមួយការជួយជ្រោមជ្រែង គេនឹងរៀនបំណិនទាំងនោះយឺតជាងកុមារដែលមើលឃើញពី 3 ទៅ 6 ខែតែប៉ុណ្ណោះ។

## សកម្មភាព

បើសិនជាកូនអ្នកអាចនៅមើលឃើញតិចតួច ចូរយកសកម្មភាពទាំងនេះទៅអនុវត្តឱ្យប្រាកដដើម្បីឱ្យកូនចេះប្រើគំហើញដែលនៅសេសសល់បានល្អបំផុត ( សូមអានជំពូកទី 4) ។

### ការយល់ដឹងអំពីវត្ថុ

ទារកដឹងថាមានវត្ថុ ( ឬ មនុស្ស) ស្ថិតនៅក្បែរគេនៅឡើយ ទោះជាពេលគេមិនអាចមើលឃើញ, ស្ទាប/ប៉ះ, ស្តាប់ឮ, ធុំក្លិន ឬ ភ្លក់រសជាតិក៏ដោយ ។ ប៉ុន្តែបើវត្ថុជ្រុះចាកចេញពីក្រសែភ្នែក ឬ វាលែងធ្វើឱ្យឮសម្លេង ទារកគិតថាវត្ថុនោះបាត់ទៅហើយ ។

ទារកដែលមិនអាចមើលឃើញច្បាស់មានការពិបាកច្រើនជាងទារកដែលមើលឃើញក្នុងការដឹងថាវត្ថុទាំងនេះ គឺនៅក្បែរខ្លួននៅឡើយ ។ ប្រការនេះដោយសារតែគេមានព័ត៌មានតិចតួចអំពីវត្ថុនោះ ។ ឧទាហរណ៍ គេមិនអាចមើលឃើញថាវត្ថុនៅក្បែរខ្លួននៅឡើយពេលវាលែងបន្លឺសម្លេង ។

➤ **វិធីជួយកូនឱ្យយល់ថាវត្ថុគឺស្ថិតនៅក្បែរខ្លួនគេនៅឡើយ នៅពេលគេមិនអាចឃើញ, មិនឮ, មិនប៉ះ, មិនដឹងរសជាតិ ឬ លែងធុំក្លិនពួកវា**



ចូរចងខ្សែជាប់នឹងប្រដាប់លេង ហើយចងភ្ជាប់វាទៅកៅអី, តុ, ខោអាវកូន ឬ កដៃ ( សូមអានទំព័រ 41) ។

ចូរយកគ្រាប់ផ្លែឈើ ឬ ដុំគ្រួសល្អិតៗដាក់ចូលក្នុងសំបកឃ្លោកទុំមូល ឬ បាល់ធ្វើដូច្នេះវាបញ្ចេញសម្លេង ពេលវារមៀល ។ បន្ទាប់មកលើកទឹកចិត្តកូនឱ្យប្រមៀលបាល់ត្រឡប់ទៅវិញ-ទៅមករវាងអ្នកនិងកូន ។ សម្លេងនោះនឹងជួយឱ្យកុមារដឹងថាមានវត្ថុនៅក្បែរ ទោះបីក្រោយពេលវាចាកចេញពីដៃរបស់គេក៏ដោយ ។



ចូរយកខ្សែចងជាប់នឹងប្រដាប់លេងដែលជាទីសំណប់ចិត្តរបស់ទារក ។ បង្ហាញខ្សែ និងប្រដាប់លេងដល់ទារក ហើយបន្ទាប់មកដាក់ប្រដាប់លេងនៅកន្លែងមួយដែលទារកឈោងមិនដល់ ។ ចូរលើកទឹកចិត្តកូនឱ្យទាញខ្សែដើម្បីយកប្រដាប់លេង ។ សូមចងចាំថាខ្សែ គឺជាវត្ថុមួយអាចបង្កគ្រោះថ្នាក់ដល់កុមារតូចៗ ចូរតាមមើលកូនឱ្យប្រាកដថា គេមិនយកខ្សែរុំព័ទ្ធជុំវិញករបស់ខ្លួន ។






ចូរបង្ហាញកូនអ្នកពីរបៀបដាក់វត្ថុទៅក្នុងប្រអប់មួយ ហើយបិទគម្របឱ្យជិត ។ បន្ទាប់មកបង្ហាញគេពីរបៀបបើកគម្របប្រអប់ ហើយស្រវារាវរកយកវត្ថុចេញមកវិញ ។








## ធ្វើអ្វីៗដូចកុមារដទៃធ្វើអញ្ចឹងដែរ (ធ្វើត្រាប់តាម)

កុមារដែលមើលឃើញរៀនយ៉ាងច្រើនដោយការមើលទៅអ្នកដទៃ និងព្យាយាមធ្វើត្រាប់តាមអ្វីដែលមនុស្សទាំងនោះធ្វើ ។ កុមារដែលមិនអាចមើលឃើញច្បាស់ ទោះជាយ៉ាងណាក៏ដោយត្រូវតែផ្ចង់ស្មារតីយកចិត្តទុកដាក់ទៅរកសម្លេង និងតម្រុយដើម្បីឱ្យដឹងថាមនុស្សកំពុងធ្វើអ្វីមួយ ។

### ➤ វិធីលើកទឹកចិត្តកូនឱ្យចេះធ្វើត្រាប់តាមអ្នកដទៃ

ចូរធ្វើត្រាប់តាមគេ ។ នៅពេលកូនអ្នកធ្វើសូរសម្លេង ចូរធ្វើសូរសម្លេងដូចគ្នានោះត្រឡប់ទៅវិញ ។




ចូរធ្វើអ្វីមួយដែលបញ្ចេញសម្លេង ហើយលើកទឹកចិត្តកូនឱ្យធ្វើតាមអ្វីដែលអ្នកបានធ្វើ ។










នៅពេលកូនធំបន្តិច ចូរលើកទឹកចិត្តគេឱ្យតែងខ្លួន ហើយតាំងខ្លួនធ្វើជានរណាម្នាក់ផ្សេង (តែងតួដើម្បីសំដែងតួ) ។

## ការយល់ដឹងអំពីហេតុអ្វីបានជាហេតុការណ៍កើតឡើង (មូលហេតុ និង ផលប៉ះពាល់)

នៅពេលទារកតូចលេងជាមួយប្រដាប់លេង គេមិនដឹងថាមានអ្វីនឹងកើតឡើងឡើយ ។ ប៉ុន្តែគេរៀនបន្តិចម្តងៗ ដោយធ្វើអ្វីមួយពិតប្រាកដ - ដូចជាគោះប្រដាប់លេងទៅលើកម្រាលផ្ទះ -គេអាចធ្វើឱ្យអ្វីៗផ្សេងទៀតកើតឡើង-ដូចជាសូរសម្លេងខ្លាំងមួយ ។ នេះគឺជាមេរៀនសំខាន់មួយចំពោះទារកពីព្រោះគេកំពុងស្វែងសិក្សាឱ្យដឹងថា គេអាចមានអនុភាពលើព្រឹត្តិការណ៍ទាំងឡាយនៅជុំវិញខ្លួនគេ ។ គេក៏រៀនផងដែរថា គេអាចមានឥទ្ធិពលខ្លះៗលើអ្វីដែលកើតឡើង ។ ប្រការនេះធ្វើឱ្យគេកាន់តែចង់ដឹងចង់ឃើញអំពីរបៀបដែលអ្វីៗមានដំណើរការ ។

### ➤ វិធីជួយទារករៀនអំពីមូលហេតុ និង ផលប៉ះពាល់

ចូរដាក់ប្រដាប់លេងដែលបញ្ចេញសម្លេងគឹកកងចងកាត់លើកន្លែងដេក ឬ កន្លែងលេងរបស់ទារក ។ ធ្វើឱ្យប្រាកដថាប្រដាប់លេងនោះចងទាបល្មមដែលឱ្យទារកអាចវាយ ឬ ធាក់វាបានដោយចៃដន្យ ។ នៅក្នុងពេលយ៉ាងខ្លី ទារកនឹងរៀនវាយ ឬ ធាក់ដោយចេតនា ។






ចូរធ្វើគំនរមួយដោយត្រួតប្រអប់តូចៗ ឬ កំប៉ុងដែលអាចឱ្យទារកច្រានវាទម្លាក់បាន ។ នៅពេលគេធំបន្តិច គេអាចរៀនធ្វើគំនរដោយខ្លួនឯង ។ ចូរលើកទឹកចិត្តឱ្យកូនឃើញថា គេអាចត្រួតវត្ថុលើគ្នាបានយ៉ាងខ្ពស់ មុនពេលច្រានទម្លាក់វា ហើយសម្គាល់សម្លេងខុសៗគ្នាដែលប្រអប់ ឬ កំប៉ុងនីមួយៗបានបញ្ចេញមក ។

ចូរលើកទឹកចិត្តកូនឱ្យដាក់របស់របរចូលក្នុងប្រអប់ ហើយរលាក់វាចេញមកវិញ ។



## ការដោះស្រាយបញ្ហា

កូនអ្នកបានរៀនអំពីការដោះស្រាយបញ្ហាមួយចំនួនរួចទៅហើយ ។ ឧទាហរណ៍ បើគេយំនៅពេលគេចង់បានអ្វីមួយ គេបានដឹងថា ការយំនឹងធ្វើឱ្យគេទទួលនូវអ្វីមួយដែលគេចង់បាន ។ តែការយំរបស់កុមារក៏មានន័យថាគេកំពុងស្នើឱ្យនរណាម្នាក់ជួយដោះស្រាយបញ្ហាឱ្យគេផងដែរ ។ កុមារត្រូវការដឹងថាគេអាចដោះស្រាយបញ្ហាជាច្រើនដោយខ្លួនឯងផ្ទាល់ ។

### ➤ វិធីជួយទារករៀនរបៀបដោះស្រាយបញ្ហា




ចូរយកកំណាត់គ្របលើមុខទារក ។ គេអាចទាញវាចេញភ្លាមមួយរំពេច ។ តែបើគេមិនទាញកំណាត់ចេញ អ្នកត្រូវទាញកំណាត់ចេញដោយខ្លួនឯង ហើយយកកំណាត់គ្របលើមុខទារកម្តងទៀត ។

ចូរលេងបិទពួនជាមួយនឹងប្រដាប់លេងរបស់កូនអ្នក ។ ក្រឡុកប្រដាប់លេងដែលធ្វើឱ្យមានសម្លេងគឹកកង ហើយលាក់វានៅក្រោមកំណាត់មួយផ្ទាំង ហើយចាំមើលតើកូនអាចទាញកំណាត់ចេញដើម្បីរកប្រដាប់លេងនោះទេ ។ បន្ទាប់មកទៀតព្យាយាមផ្កាប់ចានសម្ល ឬ ឆ្នាំង និងផ្កាប់វាពីលើប្រដាប់លេង ។ ចាំមើលតើគេអាចគិតឃើញនូវគំនិតផ្ងារឆ្នាំងឡើងដែរទេ ។




ឱ្យប្រអប់មួយដែលពេញដោយវត្ថុមានទំហំខុសៗគ្នាទៅឱ្យកូនលេង ។ ហើយចោះប្រហោងលើគម្របប្រអប់ ប៉ុន្តែត្រូវចោះឱ្យប្រហោងតូចជាងវត្ថុមួយចំនួននៅក្នុងនោះ ។ បិទគម្របប្រអប់ ហើយលើកទឹកចិត្តកូនឱ្យលូកយកវត្ថុទាំងអស់ចេញមកក្រៅ ។ ចាំមើលតើកូនអាចគិតឃើញគំនិតបើកគម្របប្រអប់ ដើម្បីយកវត្ថុដែលធំជាងគេបង្អស់ចេញមកក្រៅទេ ។



**ប្រហោងគួរតែធំល្មមសំរាប់ឱ្យដៃកុមារអាចលូកចូលក្នុងប្រអប់បាន តែប្រហោងត្រូវចោះតូចល្មម ធ្វើដូច្នេះប្រដាប់លេងធំៗមិនអាចទាញចេញតាមប្រហោងបាន។**



## ការតម្រូវគូវត្ថុ និង រៀបវត្ថុតាមលំដាប់ (តាមធុន~ប្រភេទ)

កុមារគ្រប់រូបត្រូវការរៀនពីរបៀបដែលវត្ថុមានភាពស្រដៀងគ្នា និងមានភាពខុសគ្នាទៅវិញទៅមក ។ ការតម្រូវវត្ថុនិងរៀបវត្ថុតាមលំដាប់ជួយបង្រៀនកុមារឱ្យចេះយកចិត្តទុកដាក់ចំពោះសារៈសំខាន់នៃភាពស្រដៀងគ្នា និងភាពខុសគ្នា ។

### ➤ វិធីជួយកូនរៀនពីរបៀបតម្រូវវត្ថុ

ចូរដាក់វត្ថុពីរខុសគ្នា-ដូចជាស្លាបព្រា និងឆ្នាំង នៅពីមុខកូន ហើយឱ្យកូនពិនិត្យស្ទាបស្ទង់ពួកវា ។ បន្ទាប់មកឱ្យវត្ថុទីបី ដែលដូចវត្ថុមួយក្នុងចំណោមវត្ថុពីរមុន ។ ចូរប្រាប់កូនឱ្យរកវត្ថុពីរដែលមានទ្រង់ទ្រាយដូចគ្នា ។




ចូរប្រាប់កូនអ្នកឱ្យតម្រូវវត្ថុដែលមានទំហំ ឬ ពណ៌ដូចគ្នា ឬ ដែលវាមានសម្លេងដូចគ្នា ឬ ស្ទាបទៅដូចគ្នា ។






ចោះប្រហោងលើប្រអប់ដែលមានទ្រង់ទ្រាយដូចប្រដាប់លេងសាមញ្ញមួយ ។ បន្ទាប់មកប្រាប់កូនឱ្យរកប្រដាប់លេងមួយដែលមានទ្រង់ទ្រាយដូចគ្នាដាក់ចូលក្នុងប្រអប់ ។

**➤ វិធីជួយកូនរៀនពីរបៀបរៀបវត្ថុតាមលំដាប់ ( តាមប្រភេទ ឬ ធុន)**

ចោះប្រហោងលើប្រអប់ ហើយបន្ទាប់មកប្រាប់កូនឱ្យរកប្រដាប់លេងទាំងឡាយដែលមានទំហំតូចល្មម ដែលអាចដាក់ចូលក្នុងប្រហោងប្រអប់បាន ។







ចូរលេងល្បែងកំសាន្តដោយការដាក់វត្ថុស្រដៀងៗគ្នាជាគំនរមួយ ។

ចូរលេងល្បែងកំសាន្តដោយធ្វើការប្រៀបធៀបវត្ថុ ។






ចូរបង្កើតទ្រង់ទ្រាយជាប្រភេទល្បែងល្បងប្រាជ្ញា ។ ចូរកាត់ និងចោះក្រដាសកាតុងរឹងជាទ្រង់ទ្រាយផ្សេងៗដូចជា រាងមូល និង រាងការេ ។ ជួយឱ្យកូនចេះដាក់តម្រូវពួកវាទៅកន្លែងដើមត្រឹមត្រូវវិញ ។ នៅពេលគេអាចធ្វើបែបនេះហើយ ចូរព្យាយាមឱ្យកូនអនុវត្តចំពោះទ្រង់ទ្រាយដែលពិបាកជាងមុនដូចជា រាងត្រីកោណ និង ផ្កាយ ។

## ការរាប់ចំនួន

### ➤ វិធីជួយកូនរៀនរាប់លេខ - ចំនួន

ចូររិះរកវិធីបង្រៀនកូនឱ្យចេះរាប់ចំនួននៅរៀងរាល់ពេល និង រាល់ថ្ងៃ។










នៅពេលដែលកូនអ្នកកំពុងតម្រូវវត្ថុ និងរៀបវត្ថុតាមប្រភេទ អ្នកក៏អាចបង្រៀនកូនឱ្យរាប់ចំនួនផងដែរ។

ចូរធ្វើគ្រោងឈើសាមញ្ញសំរាប់រាប់លេខ។ កូនអ្នកអាចបង្អូតអង្កាំ ឬ កងតូចៗពីម្ខាងទៅម្ខាងដើម្បីរាប់ចំនួនធ្វើលេខបូក ឬ លេខដក។

នៅពេលកូនអ្នកកាន់តែប៉ិនប្រសប់ក្នុងការរាប់ចំនួន គេអាចរៀនប្រើវិធីនេះនៅក្នុងសហគមន៍របស់អ្នក ដែលពឹងអាស្រ័យលើការប៉ះ/ស្ទាប - ដូចជារាប់ដុំថ្ម ឬ ប្រើក្បាច់គិតលេខ (អាចធ្វើស្រដៀងនឹងក្បាច់គិតលេខរបស់ចិន)។



## បង្កើនបំណិនការគិតរបស់កូន

នៅអំឡុងពេលដែលកូនអ្នកអភិវឌ្ឍ គេត្រូវតែរៀនប្រើបំណិនរបស់ខ្លួនដើម្បីបង្កើតគំនិតឱ្យកាន់តែពេញលេញអំពីព្រឹត្តិការណ៍ទាំងឡាយដែលនៅជុំវិញខ្លួន។ អ្នកអាចជួយដោយការផ្តល់ឱកាសខុសៗគ្នាជាច្រើនដល់កូន ដើម្បីឱ្យគេរៀនអំពីព្រឹត្តិការណ៍ទាំងឡាយរបស់គេ។




### ➤ វិធីបង្កើនបំណិនការគិតរបស់កូនអ្នក

ជួយកូនរៀនឱ្យកាន់តែច្រើនអំពីវត្ថុដោយការបង្រៀនគេឱ្យចេះស្ទាបរូបរាងវត្ថុទាំងមូល ទោះបីជាវាធំយ៉ាងណាក៏ដោយ។ ចូរលើកទឹកចិត្តកូនឱ្យស្វែងរកឱ្យឃើញពីទំហំ, ទ្រង់ទ្រាយ (រូបរាង), ទម្ងន់ និង ស្ទាបរូបរាងរបស់វា។

បើសិនជាកូនអ្នកនៅមើលឃើញខ្លះៗ ស្នើឱ្យកូនរៀបរាប់អំពីវត្ថុឱ្យអ្នកស្តាប់ ឬ គូររូបរបស់វត្ថុនោះ។ ប្រការនេះអ្នកនឹងបានដឹង បើកូនមើលឃើញបានគ្រប់គ្រាន់ដើម្បីស្វែងយល់ពីអ្វីទៅដែលជារូបរាងពិតប្រាកដរបស់វត្ថុ។ បើសិនជាកូនមើលមិនឃើញវត្ថុបានត្រឹមត្រូវ ចូរពន្យល់កូនថាវាមានរូបរាងបែបណា។



ចូរជួយកូនរៀនពីចំណែកទាំងអស់ដែលខុសៗគ្នានៃសកម្មភាពមួយ ។ ឧទាហរណ៍ ចូរនាំកូនអ្នកទៅជាមួយ ហើយពន្យល់កូនពីអ្វីៗដែលអ្នកត្រូវធ្វើនៅក្នុងការរៀបចំម្ហូបអាហារ ។










ចូរជួយកូនឱ្យយល់ពីរបៀបដែលវត្ថុបានប្រែប្រួល ។ ឧទាហរណ៍ នៅក្នុងឧទាហរណ៍ខាងលើស្តីពីការចំអិនអាហារ កុមារក៏អាចរៀនពីរបៀបដែលបន្លែ និងពងមាន់បានប្រែប្រួល ហើយស្ទាបវាឱ្យដឹងពីភាពខុសប្លែកក្រោយពេលចំអិនហើយ ។






ជួយកូនឱ្យចេះផ្សារភ្ជាប់ពីបទពិសោធន៍មួយទៅបទពិសោធន៍មួយទៀត ។ ឧទាហរណ៍




